២_ សក្តិប្រភេទ ៣ :

សំរាប់ពាក់លើកអាវខាងឆ្វេងនៃឯកសណ្ឋានលេខ ៧ « ឯកសណ្ឋានប្រតិបត្តិការ » ។ សក្តិ នេះមានរាងទ្រវែងខាងដើមមូល និងចុងស្រួច ធ្វើអំពីក្រណាត់កាំម៉ីផ្ទៃពណ៌ខៀវចាស់ និងម្ដុំរាជពណ៌ប្រាក់ ដោយរម្ស៊ៀកតែសក្តិថ្នាក់នាយទាំងអស់មានម្កុដរាជពណ៌មាស ។

នៅពេលពាក់សក្តិប្រភេទ៣ នេះត្រូវពាក់សញ្ញានគរបាលជាតិប្រភេទទី ៥ នៅកអាវខាងស្តាំ ។

-អំពីទំហំខ្នាត : « ដូចសក្តិថ្នាក់វរសេនីយ៍ អនុសេនីយ៍ » ។

មាត្រា ២ ._ រាល់ខ្លឹមសារណាដែលមានចែងក្នុងក្រឹត្យ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៣ ត្រូវស្ថិតនៅជាធរមានលើកលែងតែចំណុចណាដែលបានកែសំរួលដោយព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ រាល់ការផលិតសក្តិខុសពីរូបភាពទំហំខ្នាត ដែលកំណត់ក្នុងមាត្រា ១ នៃព្រះរាជក្រឹត្យនេះត្រូវហាមឃាត់ ។

មាត្រា ៤ ._ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាប់ប្អូន

ប្រមុខរដ្ឋស្តីទី

បាត្តលេខា និង ត្រា

ជា ស៊ីម

★★★

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៤ អនក្រ.បក
### ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ
### របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

******

### រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៥ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ របស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ / ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស / រកត / ១០៩៤ ៩០ / ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៨៩៧ / ១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ / បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

-តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាអង្គប្រជុំ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ ._ អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងសាធារណការ និងដឹកជញ្ជូន និង កំណត់បេសកកម្ម របស់ ក្រសួង និង មុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២ ._ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និង គ្រប់គ្រងវិស័យសាធារណការ និង ដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ ._ ក្រសួងសាធារណការ និង ដឹកជញ្ជូន មានមុខងារនិងភារកិច្ចដូចតទៅ :

-គ្រប់គ្រងការអនុវត្តន៍នយោបាយជាតិ លើវិស័យសំណង់សាធារណៈទូទៅ ដោយរៀបចំគោលការណ៍ច្បាប់ និង សហការជាមួយស្ថាប័ននានា ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ ។

-សមិទ្ធិ ថែទាំ គ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវដែក ផ្លូវទឹកនិងអាគាររដ្ឋ។

-ចាត់ចែងបទបញ្ជាស្តីពីអាជីវកម្ម លើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក ផ្លូវទឹក ។

-ចាត់ចែងបទបញ្ជា និង ត្រួតពិនិត្យលើការដឹកជញ្ជូនតាមផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក ។

-ចូលរួម និង សហការចាត់ចែងច្បាប់ បទបញ្ញត្តិ ការដ្ឋាននានាដែលពាក់ព័ន្ធនឹងសំណង់ ។

-សមិទ្ធិសំណង់ផ្សេងៗ ទៀតដែល រាជរដ្ឋាភិបាលប្រគល់អោយ

-សហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រាល់ការងារសំណង់ផ្លូវអាកាស ។

មាត្រា ៤ ._ ក្រសួងសាធារណការ និង ដឹកជញ្ជូន មានរចនាសម្ព័ន្ធ ដូចតទៅ :

-អគ្គាធិការដ្ឋាន

-អគ្គនាយកដ្ឋាន រដ្ឋបាល រួមមាន ៖

- នាយកដ្ឋាន រដ្ឋបាល
- នាយកដ្ឋាន បុគ្គលិក ធនធានមនុស្ស
- នាយកដ្ឋាន គណនេយ្យ _ ហិរញ្ញវត្ថុ
- នាយកដ្ឋាន ផែនការ

-អគ្គនាយកដ្ឋាន សាធារណការនិងសំណង់រួមមាន ៖

- នាយកដ្ឋាន ផ្លូវថ្នល់
- មជ្ឈមណ្ឌលគ្រឿងចក្រធំៗ
- មជ្ឈមណ្ឌល ស្រាវជ្រាវ បច្ចេកទេស
- នាយកដ្ឋាន សំណង់អាគារ
- នាយកដ្ឋានផ្លូវទឹក
- នាយកដ្ឋាន សំណង់ផ្លូវអាកាស

-អគ្គនាយកដ្ឋាន ដឹកជញ្ជូន រួមមាន ៖

- នាយកដ្ឋាន ដឹកជញ្ជូន ផ្លូវគោក
- នាយកដ្ឋាន ដឹកជញ្ជូន ផ្លូវទឹក
- នាយកដ្ឋាន នាវាជំនាញសមុទ្រ

-ខុទ្ទកាល័យ រដ្ឋមន្ត្រី

-អង្គភាពមូលដ្ឋាន

- មន្ទីរសាធារណការ និងដឹកជញ្ជូនតំបន់
- មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត ក្រុង

-សហគ្រាស សាធារណៈ

-អង្គភាពសំណង់អាគារសាធារណៈ នៅតាមបណ្តាក្រសួង និងស្ថាប័នសំខាន់ៗ អង្គការលេខរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## អគ្គាធិការដ្ឋាន

**មាត្រា ៥ ._** អគ្គាធិការដ្ឋានរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ទទួលបន្ទុក ៖

-ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួង ។

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ជូន ។

-អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងជាជំនួយតាមការចាំបាច់ ។

## ជំពូក ៤

## អគ្គនាយកដ្ឋាន រដ្ឋបាល

**មាត្រា ៦ ._** អគ្គនាយកដ្ឋានរដ្ឋបាល ទទួលបន្ទុកធ្វើការទំនាក់ទំនង សំរបសំរួល គ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក សំភារៈ បរិក្ខារ គណនេយ្យ ហិរញ្ញវត្ថុ ព្រមទាំងធ្វើការសិក្សានិងផែនការកម្ម ។

អគ្គនាយកដ្ឋាន ដឹកនាំដោយ អគ្គនាយកមួយរូប និងមាន អគ្គនាយករង ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋាន នេះមាននាយកដ្ឋានចំនួន ៤ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ៧ ._** នាយកដ្ឋាន រដ្ឋបាល ទទួលបន្ទុក :

-សំរបសំរួល សកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល រវាងថ្នាក់កណ្តាល និង អង្គភាពមូលដ្ឋានក្រោមចំណុះ ។

-គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ។

-សរុបនិងធ្វើរបាយការណ៍ការងារ និង សកម្មភាពផ្សេងៗ របស់ក្រសួង ។

**មាត្រា ៨ ._** នាយកដ្ឋានបុគ្គលិក ធនធានមនុស្ស ទទួលបន្ទុក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រី រាជការ និង ភ្នាក់ងារសាធារណៈរបស់ក្រសួង ដោយទំនាក់ទំនង និង រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ។

-រៀបចំលិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។

-ធ្វើកម្មវិធីពីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង ។

-វាយតម្លៃតម្រូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក ។

-រៀបចំនយោបាយបណ្តុះបណ្តាលដំបូងនិងបន្ត ដោយទំនាក់ទំនង និង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង អនុវត្តនយោបាយនោះ ។

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និង តារាងពត៌មានប្រតិបត្តិ ។

-គ្រប់គ្រងការងារសង្គមរបស់ក្រសួង

**មាត្រា ៩ ._** នាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ ទទួលបន្ទុក :

-កាន់បញ្ជីជាប្រចាំនូវសលាកបត្រនិងគណនេយ្យរូបធាតុ ។

-ពត៌មានវិទ្យាអំពីសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

-បើកតំរោងថវិកាក្រសួង និង តាមដានពីការប្រតិបត្តិ ។

-ប្រមូលចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ។

-ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា ។

-ប្រមូលផ្តុំ និង សំរបសំរួលរាល់ចំណាយរបស់ក្រសួង ។

-គ្រប់គ្រងគណនេយ្យរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

មាត្រា ១០ ._ នាយកដ្ឋាន ផែនការ ទទួលបន្ទុក :

-ប្រមូលផ្តុំតួរលេខ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំផ្គួរផ្គុំលេខវិភាគៈ និងបរិក្ខាររបស់ក្រសួង

-តាមដានការ គ្រប់គ្រងគណនីពិសេស ។

-ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិ បេឡាភាពសាធារណៈ ។

-រៀបចំ និង គ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ក្រសួង និង កំណត់កម្មវិធីអភិវឌ្ឍន៍លើគ្រប់ផ្នែក ទាំងអស់ ។

-ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេសលើវិស័យសាធារណការ និង ដឹកជញ្ជូន ។

-សំរបសំរួលជំនួយពីបរទេស និង ត្រួតពិនិត្យការអនុវត្តន៍ ។

ជំពូក ៥

អគ្គនាយកដ្ឋានសាធារណការ និង សំណង់

មាត្រា ១១ ._ អគ្គនាយកដ្ឋានសាធារណការ និង សំណង់ទទួលបន្ទុកតំរង់ទិស ណែនាំ តាមដាន និងត្រួតពិនិត្យការងារសាងសង់ ជួសជុល និង ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន តាមដានត្រួតពិនិត្យវិស័យសាងសង់អាគារ សាធារណៈ និង គ្រប់គ្រងសាងសង់ ការជួសជុល បេតិកភ័ណ្ឌ របស់រដ្ឋរាជរដ្ឋាភិបាលប្រគល់អោយក្រសួង ។

អគ្គនាយកដ្ឋាន ដឹកនាំដោយ អគ្គនាយកមួយរូប និងមានអគ្គនាយករង ជាជំនួយតាមការចាំបាច់ ។

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំនួន ៦ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

មាត្រា ១២ ._ នាយកដ្ឋានផ្លូវថ្នល់ទទួលបន្ទុក :

-សមិទ្ធិ ថែទាំ គ្រប់គ្រង និងតាំងបទបញ្ញាអាជីវកម្ម លើហេដ្ឋារចនាសម្ព័ន្ធផ្លូវ ជាអាទិ៍ ផ្លូវថ្នល់ ផ្លូវលំ សិល្បការនានា កំពង់ចម្លង សាឡាង និងថ្នល់ក្រុង ។

ក្នុងតួនាទីនេះ នាយកដ្ឋាន ផ្លូវថ្នល់ មានមុខងារពីរ :

ក / រៀបចំកម្មវិធីការងារថែទាំ និង គ្រប់គ្រងផ្លូវថ្នល់ និង ស្ពាន :

-ធ្វើសំរង់ទិន្នន័យ និង ប្រើប្រាស់ទិន្នន័យចាំបាច់ ដើម្បីយល់ដឹងពីបណ្តាញផ្លូវ ។

-គ្រប់គ្រងឯកសារបច្ចេកទេសប្រើផ្លូវ និង សិល្បការនានា ព្រមទាំងពត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងបណ្តាញផ្លូវថ្នល់ ។

-រៀបចំថវិកា បែងចែកមធ្យោបាយ តាមដាន និង ត្រួតមើលពីលើការងារថែទាំ ។

-គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ផ្លូវថ្នល់ ផ្លូវទឹក និង ផ្លូវដែក ។

ខ / គ្រប់គ្រងការដ្ឋានផ្លូវថ្នល់ និង ស្ពាន :

-សិក្សាគ្រប់គ្រង និង រៀបចំកម្មវិធីស្តីពីការថែទាំផ្លូវថ្នល់ និង ស្ពាន ។

-រៀបចំថវិកា បែងចែកមធ្យោបាយតាមដាន និង ត្រួតមើលពីលើការដ្ឋានផ្លូវថ្នល់ និង ស្ពាន ។

-វាយតម្លៃការដ្ឋានដែលសំរេចរួចហើយ ។

-គ្រប់គ្រងកំពង់ចម្លង សាឡាង ។

មាត្រា ១៣ ._ មជ្ឈមណ្ឌលគ្រឿងចក្រធំៗ ទទួលបន្ទុក :

-សិក្សាស្រាវជ្រាវ ធ្វើគំរោង និង សាងសង់ការងារថ្មី ។

-គ្រប់គ្រង និង ត្រួតពិនិត្យបរិក្ខារនិងគ្រឿងចក្រនៅក្រោមអាណាព្យាបាល ។

-សិក្សានិងរៀបចំបណ្តុះបណ្តាលបុគ្គលិកខាងគ្រឿងចក្រ ។

មាត្រា ១៤ ._ មជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស ទទួលបន្ទុក :

-រៀបចំបទដ្ឋានបច្ចេកទេស និងការងារសំរាប់អនុវត្ត ។

-សិក្សាស្រាវជ្រាវ រៀបចំគំរោងសំណង់សាធារណការ

-និទស្សន៍សំណង់ គុណភាពតំរិះ និង បច្ចេកវិធីថ្មីទំនើប សំរាប់អនុវត្តការងាររបស់ក្រសួង

មាត្រា ១៥ ._ នាយកដ្ឋាន សំណង់អាគារ ទទួលបន្ទុក :

-ចូលរួមសហការជាមួយ ស្ថាប័ននានាដើម្បី តំរង់ទិស ណែនាំ ត្រួតពិនិត្យ តាមដាន វិស័យសាងសង់អាគារ សាធារណៈ និង វិស័យបេនគរោបនីយកម្ម ។

-គ្រប់គ្រងការសាងសង់ និង ការជួសជុល បេតិកភ័ណ្ឌនានារបស់រដ្ឋ ដែលរាជរដ្ឋាភិបាលបានប្រគល់អោយ ក្រសួង ។

-សហការជាមួយស្ថាប័នផ្សេងៗ ក្នុងការបង្កើតការិយាល័យសំណង់ ។

-ស៊ើបអង្កេតសំណុំរឿងវិវាទ សំណង់អាគារ និងធ្វើកោសល្យវិច័យសំរាប់ធានាសុវត្ថិភាពសាធារណៈ ។

-កាត់តែងកម្មវិធី និង រៀបចំថវិកានៃកិច្ចសហប្រតិបត្តិការនៃបណ្តាការថែទាំធំៗ សំរាប់រដ្ឋបាល រួមទូទៅ ។

-ត្រួតពិនិត្យបច្ចេកទេស និងហរិញ្ញវត្ថុ នៃ សមិទ្ធកម្មប្រតិបត្តិការថែទាំ ។

-អនុវត្តបទបញ្ញត្តិពីអនុញ្ញាតសាងសង់ ។

-អនុវត្តបទដ្ឋានបច្ចេកទេស និង សុវត្ថិភាពការសាងសង់ ។

-សំរង់ប្រមូលនិងប្រើប្រាស់ទិន្នន័យសេដ្ឋកិច្ច នៃ [illegible] សាធារណៈ និង នគរោបនីយកម្ម ។

មាត្រា ១៦ ._ នាយកដ្ឋានផ្លូវទឹក ទទួលបន្ទុក :

-សិក្សា និង ធ្វើការងារទាំងឡាយដែលទាក់ទងជលមាគ៌ា នាវាចរណ៍ តាមផ្លូវទឹកធម្មជាតិ ។

-[illegible] និងផែនទីទន្លេ ច្រកចង្អៀត ប្រឡាយ ។

-ពសាងថ្នាក និង ពោងសញ្ញា នាវាចរណ៍ តាមផ្លូវទន្លេ ។

-រៀបចំវិធានការទាំងអស់ ដែលបង្កលក្ខណៈរាំងស្ទះ ដល់នាវាចរណ៍ និងចរន្តផ្លូវទឹក ។

-ផ្សព្វផ្សាយព័ត៌មានដំណឹងនានា ដល់អ្នកបើកបរ នូវឧបសគ្គដែលលេចឡើងថ្មី ។

-រៀបចំ[illegible]ការបើកជញ្ជូនក្បូន ផ្ទះបណ្តែតទឹក ។ល។ ចតទៅតាមកន្លែងសមស្របត្រឹមត្រូវ ។

-ពិនិត្យលើការ[illegible]សាងសង់ក្នុងទន្លេ ក្រោមទន្លេ លើអាកាសឆ្លងកាត់ទន្លេ ។

-សិក្សាស្រាវជ្រាវលើការងារ និង ការពារច្រាំងបាក់ ។

បើកវិធានការណ៍ និង បូមស្តារទន្លេអោយមានជំរៅទឹកល្អ ដើម្បីបំរើការងារដឹកជញ្ជូន ។

-សាងសង់កំពង់ផែក្នុងស្រុក ដោយសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ។

-គ្រប់គ្រងសីតណឹផ្លូវទឹក ។

-ពិនិត្យសំណើសុំយកទឹកពីទន្លេ និង បញ្ចូនទឹកមកក្នុងទន្លេវិញ ដែលអាចមានផលប៉ះពាល់ ដល់ជំរៅទឹក ។

-គសាងពន្ធ និង ចរាចរតាមមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់អាកាសនាវាចរណ៍ ។

-កត់ត្រា ស្តីពីកំពស់ទឹក តាមដងទន្លេទូទាំងប្រទេសសំរាប់ការងារចរាចរផ្លូវទឹក ។

មាត្រា ១៧ ._ នាយកដ្ឋាន សំណង់ផ្លូវអាកាស ទទួលបន្ទុកសហការជាមួយ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្នុងការងារសាងសង់អាកាសយានដ្ឋាន ៖

-សិក្សាត្រួតពិនិត្យ និងតាមដានលើគំរោងកសាងសង់អាកាសយានដ្ឋានទូទាំងប្រទេស ទាំងសំណង់ធ្វើដោយរដ្ឋ ព្រមទាំងសំណង់ធ្វើដោយឯកជន ដើម្បីផលប្រយោជន៍រដ្ឋមាន BOT ជាដើម ។

-សិក្សាជ្រើសរើស ត្រួតពិនិត្យ ទីតាំងសំណង់វាលអាកាសយានដ្ឋាន ។

-រៀបចំតាក់តែងបទដ្ឋានបច្ចេកទេស ស្តីអំពីការសាងសង់អាកាសយានដ្ឋាន ។

## ជំពូក ៦

## អគ្គនាយកដ្ឋានដឹកជញ្ជូន

មាត្រា ១៨ ._ អគ្គនាយកដ្ឋានដឹកជញ្ជូន ទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក ផ្លូវសមុទ្រ និងតាក់តែងរៀបចំបទបញ្ញត្តិទាំងឡាយ ដើម្បីសំរួលនិងធានាសន្តិសុខដល់ការធ្វើចរាចរ ។

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូបនិងមានអគ្គនាយករងជាជំនួយការ តាមការចាំបាច់។

អគ្គនាយកដ្ឋានដឹកជញ្ជូន មាននាយកដ្ឋានចំនួន ៣ ដូចមានចែងក្នុងមាត្រាខាងក្រោម ។

មាត្រា ១៩ ._ នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ទទួលបន្ទុក ៖

-រៀបចំចាត់ចែង តាក់តែងបទបញ្ញាត្រួតពិនិត្យ រក្សាសន្តិសុខនិងសំរបសំរួលការដឹកជញ្ជូនផ្លូវគោក ជាអាទិ៍ ផ្លូវថ្នល់ ផ្លូវទីក្រុងនិងផ្លូវដែក ។

ក / -ការគ្រប់គ្រង តាមពត៌មានវិទ្យាលើរាល់សកម្មភាព ៖

-ធ្វើពត៌មានវិទ្យា ប័ណ្ណបើកបរ វិញ្ញាបនបត្រចុះបញ្ជី និងលិខិតអនុញ្ញាតស្តីពីការដឹកជញ្ជូន ។

-គ្រប់គ្រងសំណុំសាលាកបត្រ នៃ វិញ្ញាបនបត្រ ។

-រៀបចំស្ថិតិ គ្រប់សកម្មភាពរបស់នាយកដ្ឋាន ។

ខ / -ការត្រួតពិនិត្យបទបញ្ញា និង ត្រួតពិនិត្យការធ្វើចរាចរ ៖

-តាក់តែងបទបញ្ញាទាំងឡាយទាក់ទងនឹងការធ្វើចរាចរតាមផ្លូវថ្នល់ ។

-ត្រួតពិនិត្យការបណ្តុះបណ្តាល មេប្រយោគប្រឡងប័ណ្ណបើកបរ និងគ្រូបង្ហាត់រថយន្តរៀនបើកបរ។

-សំរបសំរួល សកម្មភាពទប់ស្កាត់គ្រោះថ្នាក់តាមផ្លូវ និង ត្រួតពិនិត្យចរាចរតាមផ្លូវថ្នល់ ។

-ផ្តល់អោយ និង ចេញប័ណ្ណចរាចរ ។

គ / -ការរៀបចំចាត់ចែង និង ការគ្រប់គ្រងការដឹកជញ្ជូនផ្លូវគោក ៖

-សិក្សា ដាក់អោយអនុវត្តត្រួតពិនិត្យបទបញ្ជា សំរបសំរួល និងសុខដុម ការដឹកជញ្ជូនអ្នកដំណើរ។

-សិក្សានិងដាក់អោយអនុវត្តនិងត្រួតពិនិត្យបទបញ្ជា សំរបសំរួលការដឹកជញ្ជូនទំនិញតាមផ្លូវ ។

-ចេញលិខិតអនុញ្ញាតអោយដឹកជញ្ជូនអន្តរជាតិ និង ក្នុងតំបន់សំរាប់អ្នកដំណើរ និង ទំនិញ ។

-ណែនាំដល់ក្រុង និងទីប្រជុំជនក្នុងការដឹកជញ្ជូនតាមក្រុង និងទីប្រជុំជន ។

-សំរបសំរួលបច្ចេកទេសនិងតារាងតំលៃផ្លូវដែក ផ្លូវថ្នល់ ។

មាត្រា ២០ ._ នាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក ទទួលបន្ទុក :

-គ្រប់គ្រងការដឹកជញ្ជូនតាមទន្លេ-ព្រែក ស្ទឹង បឹង ។

-ចាត់ចែង និង ត្រួតពិនិត្យការគោរពបទបញ្ជានិងវិន័យនៃការដឹកជញ្ជូនតាមផ្លូវទន្លេ ។

-ត្រួតពិនិត្យ និងតាមដាននយោបាយ អភិវឌ្ឍន៍ការដឹកជញ្ជូនទាំងនោះ ។

-ចេញប័ណ្ណបើកបរ ប័ណ្ណសំគាល់នាវា ប័ណ្ណយន្តការី និងលិខិតអនុញ្ញាតធ្វើអាជីវកម្ម ។

-ត្រួតពិនិត្យ លើតំបន់ផែទាំងឡាយនៅក្នុងស្រុក ។

-ត្រួតពិនិត្យ អំពីលក្ខន្តិកៈនាវាក្នុងប្រទេស ។

មាត្រា ២១ ._ នាយកដ្ឋាននាវាជំនួញសមុទ្រ ទទួលបន្ទុក :

ក / -ការងាររដ្ឋបាលទូទៅ នៃកងនាវាជំនួញរបស់រដ្ឋ និង គ្រឹះស្ថានសាធារណៈរបស់រដ្ឋ ៖

-គ្រប់គ្រងការងារដឹកជញ្ជូនទៀងទាត់តាមផ្លូវសមុទ្រ និង ត្រួតពិនិត្យការអនុវត្តន៍បទបញ្ជាត្រួតពិនិត្យ នាវាចារកិច្ចក្រៅកិច្ចព្រមព្រៀង ( armements hors eonferenec )

-ស្រាវជ្រាវ ដើម្បីបញ្ចូលនាវាវិចារកិច្ចរបស់រដ្ឋ ក្នុងចលនាដឹកនាំតាមឯកទេស ។

-សិក្សា និង វាយតម្លៃគុណភាពនិងបរិមាណតំរូវការរបស់រដ្ឋស្តីពីកងនាវាជំនួញ ។

-សិក្សា ដើម្បីតាវការបិកល្អនៃ នាវាវិចារកិច្ចរបស់រដ្ឋ ។

-ស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេសស្តីពីទស្សនាវដ្តី ។

-ណែនាំឯកសារបច្ចេកទេស ជំនួយដល់ការវិនិយោគនាវាចរ ។

-រៀបចំបែបបទ អំពីលក្ខន្តិកៈនាវាសមុទ្រ ។

ខ / -ការងារសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់ និង អន្តរជាតិ :

-ចាត់ចែង និង ស្នើមូលដ្ឋានបច្ចេកទេសនៃកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់និងអន្តរជាតិ ។

-គ្រប់គ្រងកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រក្នុងតំបន់ និង អន្តរជាតិ ។

-គ្រប់គ្រងកិច្ចព្រមព្រៀងទ្វេភាគីនៃកិច្ចសហប្រតិបត្តិការក្នុងវិស័យដឹកជញ្ជូនតាមផ្លូវសមុទ្រ ។

-ចរចាជាអន្តរជាតិក្នុងវិស័យដឹកជញ្ជូនតាមសមុទ្រ ។

គ / -គ្រប់គ្រងវិជ្ជាជីវៈបន្ទាប់បន្សំក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រ ។

## ជំពូក ៧
## ខុទ្ទកាល័យ រដ្ឋមន្ត្រី

មាត្រា ២២ ._ ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលមានកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យ លេខ ២០ អនក្រ . បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៨
## អង្គភាពមូលដ្ឋាន

មាត្រា ២៣ ._ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា មានមន្ទីរសាធារណការនិងដឹកជញ្ជូនតំបន់ និង មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គភាពមូលដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ មួយដោយឡែក ។

## ជំពូក ៩
## សហគ្រាសសាធារណៈ

មាត្រា ២៤ ._ ក្រសួងសាធារណការ និង ដឹកជញ្ជូន [illegible] សហគ្រាសសាធារណៈ ដូចខាងក្រោម ៖

I / អង្គភាពដែលស្ថិតក្រោមអនុក្រឹត្យលេខ ៥១ អនក្រ . បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៦

II / សហគ្រាសសាធារណៈក្រោមអាណាព្យាបាលមានលក្ខន្តិកៈ កំណត់ក្នុងពេលខាងមុខ ៖

- ១- រាជាយស្ម័យយានកម្ពុជា
- ២- កំពង់ផែ ក្រុងព្រះសីហនុ
- ៣- កំពង់ផែ ភ្នំពេញ
- ៤- នាយកដ្ឋាន ភ្នាក់ងារកម្ពុជានាវាចរ ( កាំសាប )
- ៥- ក្រុមហ៊ុន ដឹកជញ្ជូនដោយរថយន្ត
- ៦- ក្រុមហ៊ុន ដឹកជញ្ជូនអ្នកដំណើរ
- ៧- នាយកដ្ឋាន សំភារៈ
- ៨- សហគ្រាស សំណង់ភ្នំពេញ
- ៩- សហគ្រាស គ្រឿងចក្រសំណង់ផ្លូវថ្នល់
- ១០- សហគ្រាស សិក្សាស្រាវជ្រាវ ផ្លូវថ្នល់
- ១១- សហគ្រាស សំណង់កំពង់ចាម
- ១២- សហគ្រាស សំភារៈដឹកជញ្ជូន
- ១៣- សហគ្រាស គ្រួសខ្សាច់ សាងសង់
- ១៤- សហគ្រាស សំណង់សិល្បការ្យ
- ១៥- រោងចក្រ ឥដ្ឋពណ៌

★ ★ ★

១៦- គាណា បង្រៀនបើកបររថយន្ត

ខ / -អង្គភាពផ្ទុយមានកិច្ចសន្យា និង នីតិវិធីកំពុងដំណើរការ :

១៧- រោងចក្រ អារឈើ

១៨- រោងចក្រ ឡឥដ្ឋ

១៩- រោងចក្រ ហ្វ្រេប្រូស៊ីម៉ង់ត៍

២០- រោងជាង ជួសជុលរថយន្ត ៧ មករា

II- សហគ្រាសសាធារណៈ មានលក្ខន្តិកៈកំណត់រួចហើយ :

ក / -គ្រឹះស្ថានសាធារណៈ មានឧបនិស្ស័យសេដ្ឋកិច្ច :

-មន្ទីរពិសោធន៍សំណង់ និង សាធារណការ ( ម.ព.ស.ស )

ខ / -សហគ្រាសសាធារណៈ រដ្ឋចំរុះឯកជន :

-ក្រុមហ៊ុន កម្ពុជានាវាដឹកជញ្ជូន ( កាំប្រង់ស៊ីប )

## ជំពូក ១០

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៥ ._** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុង អនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១១

## អវសានប្បញ្ញត្តិ

**មាត្រា ២៦ ._** ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

**មាត្រា ២៧ ._** បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨ ._** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ២៩ ._** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

# អង្គការលេខរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

